## សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺរលាកសួតបង្កឡើងដោយបាក់តេរីនូមូកូខល (Pneumococcal Conjugate Vaccine (PCV13))

## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺ អាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ការចាក់ថ្នាំវ៉ាក់សាំងអាចការពារទាំងកុមារ និងមនុស្សពេញវ័យ ចំពោះ **ជំងឺរលាកសួត**។

ជំងឺរលាកសួត បង្កឡើងដោយបាក់តេរីនូមូកូខល ដែលអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមការប៉ះពាល់ផ្ទាល់។ ជំងឺនេះអាចបង្កឲ្យកើតជំងឺត្រចៀក ហើយវាក៏អាចបណ្តាលឲ្យកើតជំងឺធ្ងន់ធ្ងរលើ៖

- សួត (ជំងឺហើមសួត)
- ឈាម (ជំងឺមានបាក់តេរីក្នុងឈាម) និង
- ស្រោមខួរក្បាល និងឆ្អឹងខ្នង (ជំងឺរលាកស្រោមខួរ)។

ជំងឺរលាកសួតបង្កឡើងដោយបាក់តេរីនូមូកូខល គឺជាជំងឺកើតទូទៅបំផុតក្នុងចំណោមមនុស្សពេញវ័យ។ ជំងឺរលាកស្រោមខួរបង្កឡើងដោយបាក់តេរីនូមូកូខល អាចធ្វើឲ្យថ្លង់ និងខូចខួរក្បាល ហើយវាសម្លាប់កុមារ 1 នាក់ ក្នុងចំណោម 10 នាក់ ដែលកើតជំងឺនេះ។

ជនណាក៏ដោយ អាចកើតជំងឺរលាកសួតបង្កឡើងដោយបាក់តេរីនូមូកូខលបាន ប៉ុន្តែ កុមារអាយុក្រោម 2 ឆ្នាំ និងមនុស្សពេញវ័យអាយុ 65 ឆ្នាំ និងច្រើនជាងនេះ មនុស្សដែលមានបញ្ហាសុខភាពមួយចំនួន និងអ្នកជក់បារី ជាបុគ្គលដែលស្ថិតក្នុងហានិភ័យ។

មុនពេលមានថ្នាំវ៉ាក់សាំង នៅសហរដ្ឋអាមេរិក៖

- មានជំងឺរលាកស្រោមខួរជាង 700 ករណី
- មានជំងឺឆ្លងក្នុងឈាមប្រហែល 13,000 ករណី
- មានជំងឺត្រចៀកប្រហែល 5 លានករណី និង
- ករណីស្លាប់មាន 200 ករណី

ចំពោះក្រោម 5 ឆ្នាំ រៀងរាល់ឆ្នាំ ដោយសារតែជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខល។ ចាប់តាំងពីមានថ្នាំវ៉ាក់សាំង ជំងឺរលាកសួតធ្ងន់ធ្ងរដោយសារបាក់តេរីនូមូកូខល ក្នុងខ្លួនកុមារទាំងនេះ បានធ្លាក់ចុះចំនួន 88%។

មនុស្សពេញវ័យប្រហែល 18,000 នាក់ បានស្លាប់បាត់បង់ជីវិតដោយសារតែជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខល នៅសហរដ្ឋអាមេរិក។

ការព្យាបាលជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខល ដោយប្រើថ្នាំប៉េនីស៊ីលីន និងថ្នាំដទៃទៀត ពុំមានប្រសិទ្ធភាព ដូចមុនទេ ដោយសារតែជំងឺនេះប្រភេទខ្លះ បានស៊ាំទៅនឹងថ្នាំទាំងនេះ។ ករណីនេះបានធ្វើឲ្យការបង្ការជំងឺនេះតាមរយៈការចាក់ថ្នាំវ៉ាក់សាំងកាន់តែមានសារៈសំខាន់ថែមទៀត។

## 2 ថ្នាំវ៉ាក់សាំង PCV13

ថ្នាំវ៉ាក់សាំងជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខល (Pneumococcal conjugate vaccine) (ហៅថា PCV13) ការពារប្រឆាំងបាក់តេរីនូមូកូខល បាន13 ប្រភេទ។

ថ្នាំវ៉ាក់សាំង PCV13 ជាធម្មតា ចាក់ឲ្យកុមារ នៅអាយុ 2 ខែ 4 ខែ 6 ខែ និង 12-15 ខែ។ ថ្នាំវ៉ាក់សាំងនេះ ក៏ត្រូវបានណែនាំឲ្យចាក់សម្រាប់កុមារ និងមនុស្សពេញវ័យនៅអាយុ 2 ឆ្នាំ ដល់ 64 ឆ្នាំ ដែលមានបញ្ហាសុខភាពមួយចំនួន និងចំពោះមនុស្សពេញវ័យទាំងអស់ដែលមានអាយុ 65 ឆ្នាំ និងលើសនេះ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់ព័ត៌មានលម្អិតដល់លោកអ្នក។

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាក់វ៉ាក់សាំងនេះ។

ជនណាក៏ដោយ ដែលធ្លាប់មានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់ជីវិត ចំពោះដូសថ្នាំវ៉ាក់សាំងនេះ ចំពោះថ្នាំវ៉ាក់សាំងជំងឺរលាកសួតដោយសារបាក់តេរីនូមូកូខលមុន ដែលហៅថា PCV7 ឬថ្នាំវ៉ាក់សាំងណាដែលមានសារធាតុ diphtheria toxoid (ឧទាហរណ៍ DTaP) មិនគួរទទួលថ្នាក់វ៉ាក់សាំង PCV13 ទេ។

ជនណាក៏ដោយ ដែលមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំង PCV13 មិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។ *សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើបុគ្គល ដែលបានចាក់ថ្នាំវ៉ាក់សាំង មានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។*

ប្រសិនបើបុគ្គល ដែលគ្រោងចាក់ថ្នាំវ៉ាក់សាំង ពុំមានសុខភាពល្អ អ្នកផ្តល់សេវាសុខភាពរបស់លោកអ្នក អាចសម្រេចកំណត់ពេលចាក់ថ្នាំទៅថ្ងៃក្រោយ។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះ មានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង ប៉ុន្តែប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។

បញ្ហាផលរំខាន ដែលបានរាយការណ៍បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង PCV13 ប្រែប្រួលតាមអាយុ និងដូសក្នុងស៊េរី។ បញ្ហាផលរំខានទូទៅបំផុត ដែលបានរាយការណ៍ក្នុងចំណោមកុមារ រួមមាន៖

- កុមារប្រហែលពាក់កណ្តាល ងងុយដេក បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង បាត់បង់ចំណង់អាហារជាបណ្តោះអាសន្ន ឬឡើងក្រហម ឬទន់ នៅត្រង់កន្លែងចាក់ថ្នាំវ៉ាក់សាំង។
- កុមារប្រហែល 1 នាក់ ក្នុងចំណោម 3 នាក់ ហើម ត្រង់កន្លែងចាក់ថ្នាំវ៉ាក់សាំង។
- កុមារប្រហែល 1 នាក់ ក្នុងចំណោម 3 នាក់ មានជំងឺគ្រុនក្តៅស្រាល ហើយប្រហែល 1 ម្នាក់ ក្នុងចំណោម 20 នាក់ មានជំងឺគ្រុនក្តៅ ដែលមានសីតុណ្ហភាពលើសពី 39°C (102.2°F)។
- កុមារប្រហែលដល់ 8 នាក់ ក្នុងចំណោម 10 នាក់ មួរម៉ៅ ឬឆាប់ខឹង។

មនុស្សពេញវ័យ បានរាយការណ៍ពីការឈឺចាប់ បញ្ហាឡើងក្រហម និងហើម នៅកន្លែងចាក់ថ្នាំវ៉ាក់សាំង។ គ្រុនក្តៅកម្រិតស្រាល ណឿយហត់ ឈឺក្បាល គ្រុនរងារ ឬឈឺចាប់សាច់ដុំ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

កុមារដែលបានទទួលថ្នាំវ៉ាក់សាំង PCV13 ព្រមទាំងថ្នាំវ៉ាក់សាំងផ្តាសាយដែលមេរោគអសកម្ម នៅពេលដំណាលគ្នា អាចមានហានិភ័យខ្ពស់ក្នុងការកើតជំងឺប្រកាច់ ដោយសារតែគ្រុនក្តៅ។ សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកសម្រាប់ព័ត៌មានបន្ថែម។

**បញ្ហាដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងណាក៏ដោយ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនអាចឈឺចុកចាប់ខ្លាំងត្រង់ស្មា ហើយពិបាកកម្រើកដៃ ដែលចាក់ថ្នាំវ៉ាក់សាំង។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយ អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើង ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំង តែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.cdc.gov/vaccinesafety/**

## 5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ — ជាធម្មតា ក្នុងរយៈពេលប៉ុន្មាននាទី ទៅប៉ុន្មានម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ ឬក៏ទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។

  ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS) (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង)។វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (VICP) (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅគេហទំព័រ VICP នៅ **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់ សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទង Centers for Disease Control and Prevention (CDC) (មជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង)
  - ទូរស័ព្ទមកលេខ**1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅគេហទំព័រ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement

**PCV13 Vaccine**

11/05/2015 Khmer

42 U.S.C. § 300aa-26

Office Use Only

Translation provided by the Immunization Action Coalition